ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ.......សហវ.ប្រក

# ប្រកាស
## ស្តីពី
## ការបង្កើត និងដាក់ឱ្យដំណើរការក្រុមការងារភាពជាដៃគូអគ្គនាយកដ្ឋានពន្ធដារ-សភាពាណិជ្ជកម្មចិន (កម្ពុជា)

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## សម្រេច

**ប្រការ ១.-**

បង្កើត និងដាក់ឱ្យដំណើរការក្រុមការងារភាពជាដៃគូអគ្គនាយកដ្ឋានពន្ធដារ-សភាពាណិជ្ជកម្មចិន (កម្ពុជា) ដែលមានសមាសភាព ដូចខាងក្រោម÷

**ក- សមាសភាពសមាជិកមកពីអគ្គនាយកដ្ឋានពន្ធដារ ÷**

| | | |
|---|---|---|
| ១- ឯកឧត្តម **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ | សហប្រធាន |
| ២- ឯកឧត្តម **អ៊ុំ សីហា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សហអនុប្រធាន |



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92,Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ:៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax: 855-23-427 798

| | | |
|---|---|---|
| ៣- ឯកឧត្តម **ជាម ជាទុច** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៤- ឯកឧត្តម **ម៉ាន់ ពុទ្ធិពល** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៥- ឯកឧត្តម **ម៉ិញ ឈានកុសល** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៦- ឯកឧត្តម **កែន សម្បត្តិ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៧- ឯកឧត្តម **ហេង សុខណាង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៨- លោកជំទាវ **ប៊ុន នារី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៩- លោក **វ័ន្ត មុនី** | ប្រធាននាយកដ្ឋានសវនកម្មសហគ្រាស | សមាជិក |
| ១០-លោក **អេង តេលា** | ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ | សមាជិក |
| ១១-ហោក **ឌី សុខុន** | ប្រធាននាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធតូច និងមធ្យម | សមាជិក |
| ១២-លោក **សេង ជាសិទ្ធ** | ប្រធាននាយកដ្ឋាននីតិកម្ម គោលនយោបាយសារពើពន្ធ និងសហប្រតិបត្តិការពន្ធដារអន្តរជាតិ | លេខាធិការ |

**ខ- សមាសភាពសមាជិកមកពីសភាពាណិជ្ជកម្មចិន (កម្ពុជា) ÷**

| | | |
|---|---|---|
| ១- លោក Jing Jun | ប្រធានសភាពាណិជ្ជកម្មចិន (កម្ពុជា) | សហប្រធាន |
| ២- លោក Tian Zhong Jin | អនុប្រធានសភាពាណិជ្ជកម្មចិន (កម្ពុជា) | សហអនុប្រធាន |
| ៣- លោក Cao Jian Jiang | អនុប្រធានសភាពាណិជ្ជកម្មចិន (កម្ពុជា) | សហអនុប្រធាន |
| ៤- លោក Le Jian Hua | អនុប្រធានប្រតិបត្តិសភាពាណិជ្ជកម្មចិន (កម្ពុជា) | សមាជិក |
| ៥- លោក Michael | អនុប្រធានសភាពាណិជ្ជកម្មចិន (កម្ពុជា) | សមាជិក |
| ៦- លោក Shen Xin Xiang | អនុប្រធានសភាពាណិជ្ជកម្មចិន (កម្ពុជា) | សមាជិក |
| ៧- លោកស្រី Wang Jian Hong | អនុប្រធានសភាពាណិជ្ជកម្មចិន (កម្ពុជា) | សមាជិក |
| ៨- លោក Jiang Hou Feng | អនុប្រធានសភាពាណិជ្ជកម្មចិន (កម្ពុជា) | សមាជិក |
| ៩- លោក Wang Jie Shui | អនុប្រធានប្រតិបត្តិសភាពាណិជ្ជកម្មចិន (កម្ពុជា) | សមាជិក |
| ១០-លោក Shi Li Jie | អនុប្រធានសភាពាណិជ្ជកម្មចិន (កម្ពុជា) | សមាជិក |
| ១១-លោក Tan Khee Meng | ទីប្រឹក្សានៃសភាពាណិជ្ជកម្មចិន (កម្ពុជា) | ទីប្រឹក្សា |
| ១២-លោក Jin Hui | លេខាធិការសភាពាណិជ្ជកម្មចិន (កម្ពុជា) | លេខាធិការ |

**ប្រការ ២.-**

ក្រុមការងារនេះ មានភារកិច្ច ក្នុងភាពជាដៃគូ អនុវត្តនូវការងារ ដូចខាងក្រោម÷

- ពិនិត្យការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារដែលកំពុងមានជាធរមាន
- ពិនិត្យនិងបកស្រាយឱ្យបានត្រឹមត្រូវនូវច្បាប់និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងពន្ធដារ ដែលមានភាពមិនច្បាស់លាស់ព្រមទាំងកែសម្រួល និងបង្កើតបទប្បញ្ញត្តិចាំបាច់មួយចំនួន
- ពិនិត្យបញ្ហានានាទាក់ទិននឹងការអនុវត្ត វិធាន និងនីតិវិធីសារពើពន្ធ សំដៅបង្កើនជំនឿទុកចិត្តរបស់អ្នកជាប់ពន្ធ និងដើម្បីធានាដល់ការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ។



hk

**ប្រការ ៣.-**

សហប្រធាននៃក្រុមការងារនេះ ត្រូវដឹកនាំការប្រជុំរាល់ប្រាំមួយខែម្តង ឬតាមការចាំបាច់។ ក្នុងករណីសហប្រធានណាមួយអវត្តមាន សហប្រធាននោះអាចជ្រើសរើសសហអនុប្រធាន ឬតំណាងរបស់ខ្លួនដើម្បីដឹកនាំអង្គប្រជុំ។

**ប្រការ ៤.-**

សហប្រធាន សហអនុប្រធាន និងសមាជិកនៃក្រុមការងារភាពជាដៃគូអគ្គនាយកដ្ឋានពន្ធដារ-សភាពាណិជ្ជកម្មចិន (កម្ពុជា) ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- សភាពាណិជ្ជកម្មនៃប្រទេសចិន "ដើម្បីជូនជ្រាប"
- ដូចប្រការ ៤ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ